Reçu le 21-9-49
RÉGIE DU DÉPÔT LÉGAL

## ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្តីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ១ លេខ ៥

Janvier

ខែមករា ព. ស. ២៤៩២

ឆ្នាំសិក្សា ១៩៤៩-៥០

ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង


| | ទំព័រ |
|---|---|
| សាលាបាឡីរងវត្តឧណ្ណាលោម | ៣ |
| ប្រែពាក្យ បារាំង - ខ្មែរ | ៥ |
| ឧត្តមដ្ឋាន | ៧ |
| មជ្ឈិមដ្ឋានទី ២ | ៩ |
| មជ្ឈិមដ្ឋានទី ១ | ១១ |
| វេយ្យាករណ៍ | ១៣ |
| អាទិកដ្ឋាន - ភាសា | ១៣ |
| អាទិកដ្ឋាន-គណិត | ២៤ |
| កុមារដ្ឋាន - គណិត | ២៦ |
| អាទិកដ្ឋាន - វត្ថុស្វាធ្យាយន៍ | ៣១ |
| វិធីបង្ការរោគ | ៣៥ |
| លោកនីតិ | ៣៧ |
| មេសូត្រតមាត់ | ៤៣ |

## សាលាបាឡីរងវិត្តឧណ្ណាលោម

ថ្ងៃទី ១ កញ្ញា គ.ស. ១៩៤៨ (ព.ស. ២៤៩១)

បញ្ចមី (ត)

ក) "**ជាង**" ហៅថា វិភត្តាបាទាន, ឧ. អក្សរលោកល្អជាងអក្សរខ្ញុំ មានអក្សរស្មៀនខ្លះអន់ជាងអក្សរខ្ញុំទៅទៀត ។

ឆដ្ឋី

៦ – ឆដ្ឋីវិភត្តិ ប្រើពាក្យជាអាយតនិបាតដូចខាងក្រោមនេះ

ក) "នៃ,របស់" ហៅថា សាមិសម្ពន្ធ: ឧ. បរិយានៃបណ្ឌិតគួរអ្នកផងយកតម្រាប់តាម ។ នេះផ្ទះរបស់ខ្ញុំ, នុះផ្ទះរបស់បងស្រីខ្ញុំ, ឯណោះរបស់ប្អូនប្រុសខ្ញុំ ។

ខ) "នៃ" (សម្រាប់ប្រើជាមួយនឹងពាក្យជា សមូហនាម (Nom collectif) ថា "ប្រជុំ, ហ្វូង, ពួក, បន, ក្រុម ។ល។" ហៅថា សមូហសម្ពន្ធ: ឧ. ប្រជុំនៃជនានុជន ។ ហ្វូងនៃគោ ។ ពួកនៃអ្នករៀន ។ បននៃអ្នកស៊ីផឹក ។ ក្រុមនៃស្នូនឆ្នាំង ។ ប្រើ សមូហសម្ពន្ធ: ជា ពហុវចនៈ ថា "នៃ-ទាំងឡាយ" ក៏បានតាមគួរដល់ដំណើរសេចក្ដី ។

គ) "នៃ" (សម្រាប់ប្រើជាមួយនឹងពាក្យ "ភារៈ, ភាព, សភាព") ហៅថា ការកិសម្ពន្ធៈ, ឧ. ភារនៃអ្នកបួស ។ ភាពនៃបុរស ។ សភាពនៃបណ្ឌិត ។

ឃ) "កាល, កាលដែល, កាលបើ" ហៅថា អធានរៈ។ ឧ. កាលគេមកអ្នកមិននិយាយនឹងគេ, លុះដល់គេទៅបាត់ទៅហើយទើបបានអ្នកនិយាយ ។(១) កាលដែលគេកំពុងឈ្លោះគ្នា ខ្ញុំពុំបានជាតាំងចិត្តស្តាប់ ។ កាលបើគេបានឲ្យប្រាក់គ្រប់ចំនួនមកឯង សឹមឯងប្រគល់របស់នេះឲ្យទៅគេ ។

(១)– ទាល់តែគេទៅបាត់ទៅហើយ ទើបបានអ្នកនិយាយ ។ ប្រើយ៉ាងនេះវិញក៏បាន ។

## Mots à traduire (suite)

| | |
|---|---|
| Concret . . . . . . . . . . . . : | រូបី |
| Abstrait . . . . . . . . . . . : | អរូបី |
| Nom concret . . . . . . . . : | រូបនាម |
| Nom abstrait . . . . . . . . : | អរូបនាម |
| Baie . . . . . . . . . . . . : | ឆកសមុទ្រ |
| Golfe . . . . . . . . . . . . . : | ឈូងសមុទ្រ |
| Prendre acte . . . . . . . . . : | ទទួលអាញត្តិ |
| Prestige . . . . . . . . . . . : | កិត្យានុភាព |
| Manifestation . . . . . . . . : | បាតុកម្ម |
| Avertir . . . . . . . . . . . . : | ព្រមាន |
| Avertissement . . . . . . . . : | ការព្រមាន |
| Sens pratique . . . . . . . . : | ន័យប្រតិបត្តិ |
| Fermeté . . . . . . . . . . . . : | សេចក្ដីមុឹងម៉ាត់ |
| Accrochage . . . . . . . . . . : | ការតើបតយុទ្ធ |
| Pharmacie centrale d'approvisionnement de l'assistance médicale . . . . . . . . . . : | ឱសុថស្ថានកណ្ដាលផ្គង់ផល់គីលានសង្គ្រោះ |
| Laboratoire de chimie . . . . : | ទីពិសោធគីមី |
| Institut de Biologie . . . . . . : | វិទ្យាឋានជីវសាស្ត្រ |
| Institut Antirabique . . . . . . : | វិទ្យាឋានបដិបក្ខឆ្កួតរោគ |
| Anti . . . . . . . . . . . . . . : | បដិបក្ខ |
| Services extérieurs . . . . . . : | ក្រុមខាងក្រៅ |
| Services Municipaux . . . : | ក្រុមរាជការក្រុង |
| Clinique ophtalmologique et oto-rhino-laryngologique . . | មន្ទីរចក្ខុ-សោតៈ-ឃានៈ-កណ្ឋរោគ |
| Médecin des Hôpitaux Psychiatriques . . . . . . . . . . : | គ្រូពេទ្យឧត្តមវិជ្ជាវិកលចរិត |

Infirmerie . . . . . . . . . . : គិលានដ្ឋាន
Service d'hygiène . . . . . . . : ក្រុមអនាម័យ
Quartier général . . . . . . . : ទីបញ្ជាការ (ទាហាន)
Etat major . . . . . . . . . . : សេនាធិការ
Transmissions . . . . . . . : ក្រុមនាំសារ
Transmission . . . . . . . . : ការនាំសារ
Compagnie des parachutistes . : កងអនុសេនាធំនៃទាហានឆ័ត្រយោង
Commando . . . . . . . . . . : កងពិសេស
Officier de liaison . . . . . . : នាយទាហានសម្ព័ន្ធ
Agent de liaison . . . . . . . : ភ្នាក់ងារសម្ព័ន្ធ
Calquer . . . . . . . . . . . . : ផ្ទាប់ចម្លង
Papier calquer . . . . . . . . : ក្រដាស់ផ្ទាប់ចម្លង
Recensement . . . . . . . . . : ការជំរឿន
Recenseur . . . . . . . . . . : អ្នកជំរឿន
Contrôle . . . . . . . . . . . . : ការត្រួត
Incompatible . . . . . . . . . : ដែលមិនចុះសម្រុង
Compatible . . . . . . . . . . . : ដែលចុះសម្រុង
Papier carbone . . . . . . . : ក្រដាស់ត្បូង
Papier pelure . . . . . . . . . : ក្រដាស់ស្តើង
Translucide . . . . . . . . . . : ឈ្វេង
Transparent. . . . . . . . . . : ធ្វង់
Opaque . . . . . . . . . . . . : ឃ្មឹក
Prévoté militaire khmer . . . : ក្រុមត្រួតទាហានខ្មែរ
Prévot . . . . . . . . . . . . . : នាយកត្រួតទាហាន
Poste militaire . . . . . . . . : ទីកងទាហាន
Brigade de police spéciale . . : កងប៉ូលិសពិសេស
Hiérarchie . . . . . . . . . . . : លំដាប់ស័ក្តិ

| | |
|---|---|
| Commandant (fonct) . . . . : | អ្នកបញ្ជាការ, (សម្រាប់ឧត្តមសេនីយ) អ្នកបង្គាប់ការ, (សម្រាប់វរសេនីយ) អ្នកកាន់កាប់ការ (សម្រាប់អនុសេនីយ) |
| Peloton . . . . . . . . . . : | ពួកទាហាន |
| Patrouille . . . . . . . . . : | ការល្បាត |
| Reconnaissance . . . . . . : | ការឈ្លបយកការណ៍ (ទាហាន) |
| Passer . . . . . . . . . . . : | ពាន, កន្លង |
| Exploitation . . . . . . . . : | អាជីវកម្ម |
| Taxe sur le chiffre d'affaire . . : | អាករលើផលរបរ |

## ឧត្តមដ្ឋាន

# ពីស្ទឹងត្រែងទៅហាណូយដោយអាកាសយាន

យើងឡើងលើយានស្រេចហើយ យានក៏ហោះឡើង នោះខ្ញុំស្ញើបពេក ថ្លែងពុំបាន ។ ខ្ញុំតាំងបណ្ដាក់ឬប្រែខ្លួនពីគ្រោះថ្នាក់ផ្សេងៗ ប៉ុន្តែគ្មានអ្វីជាកម្រើដល់ខ្ញុំឡើយ ។ ខ្ញុំប្រឹងបើកភ្នែកសំឡឹងទៅសព្វគ្រប់អំពីអាកាស យានក៏បះតែឡើងទៅលើកន្ទុំជំរៅមេឃ ។ នោះពីក្រោមយើងៗ ឃើញទន្លេដូចបន្ទះសំពត់តូចឆ្មារ ។ ឃើញផ្ទះគ្រឹះហាងស្រុកភូមិដូចជាពំនូកតូចៗ មនុស្សម្នាក្រោបទៅមក តូចៗដូចស្រមោច ។ អាកាសយានហោះឥតឈប់ រំលងភ្នំ រំលងព្រៃទាំងពេក យើងចូលជិតសមុទ្រពេក ។ ពីនោះយើងប្រែទិសដៅមួយ

ទៀតស្រែអាចគឺផងនិងទន្លេមេគង្គ ។ អាកាសយានហោះខ្ពស់ឡើងទៀត ដើម្បីរំលងជួរភ្នំអណ្ណាម នោះពីចម្ងាយឃើញវាលធំល្ហល្ហៅ គឺសមុទ្រ ឃើញទីក្រុងហៃផុងៗ ឃើញផ្លូវនានាឆ្វាដូចសរសៃអម្បោះ ឃើញវាលស្រែវែង ក្រឡាញ៉ឹកល្អិតប្រកិតគ្នា គឺត្រង់ណោះហើយដែនគុនមីង ។ អាកាសយានក៏បំបុងចុះលឿន ដូចត្រញ្ញង្គកាលចាប់ម៉ៃ ដែលជាកាលសំចតអាកាសយាននៃក្រុងហាណូយ ។

១.– ក្នុងរឿងនេះគេនិយាយពីអ្វី ?

២.– សព្ទជាដូចម្តេច = ស្មៀប – កម្ពុ ?

៣.– ចូររៀបរាប់យានដែលជាយានទំនើប ?

៤.– ស្ទឹងក្រែងជាផលបទក្នុងប្រទេសណា ?-ហាណូយជាធានីរបស់ស្រុកណា ?

៥.– ពាក្យទាំងនេះសរសេរយ៉ាងណាទៀតបាន = សមុទ្រ – បរពត ?

(អានពាក្យ = បរពត (ប-រៈ-ពត់)

# ប្រក្រតិទិននៃអ្នកកង្វាក់

ពេលវេលាមិនដែលយូរដល់ខ្ញុំ នៅក្រៅផ្ទះ កាលណាមេឃល្អ ខ្ញុំអង្គុយហាលថ្ងៃ នៅកន្លែងមួយស្រួល ផ្អែកនឹងកំពែង ផ្អែកនឹងគូបចិញ្ចឹមឃ្មុំ ផ្អែកនឹងដើមសាគៃញ នោះខ្ញុំឃើញដោយគំនិតដូចជាខ្ញុំបានឃើញពីដើមដោយភ្នែកប្រែកប្រលង ឃើញវាំង ឃើញកំពូលកេនដូង ឃើញផ្ទះហុយផ្សែង

ឃើញគោដែលស៊ីស្មៅ ឃើញអ្នកដំណើរដែលដើរហួសទៅហើយ ចរចាកាន់តាមណ្តើរលើផ្លូវ ។ ខ្ញុំស្គាល់រដូវទាំងអស់ ដូចនៅក្នុងកាលដែលធញ្ញជាតិលាស់ខៀវស្រងាត់ គេច្រូតស្មៅ ស្រូវសាលីទុំ ស្លឹកសាកែញេក្រហម ផ្លែព្រូនស្រគាល សកុណសត្វទំលើគុម្ពោត ។ ខ្ញុំមានកែកក្នុងត្រចៀក មានកែកណៃដៃ កែកនៅក្រោមជើង ។ ខ្ញុំស្អាប់អស់ម៉ាននៅប្រែចសំបុកឃ្មុំ ព្រួតពេមនឹងរះក្រោមចំពើង ។ អ្នកឃើញឬទេ គឺប្រក្រតីទិនរបស់ខ្ញុំ នឹងនាឡិកាដៃនៃខ្ញុំ ។ ខ្ញុំនិយាយពីខ្លួនខ្ញុំថាៈ ទុំះហ៊ុំតាវយុំ គឺខែមាឃ ហើយយើងបានទូរក្តៅ ទុំះហ៊ុំសារតាហួច គឺខែអាព្រិល មើលហ៊ុំសត្វល្អាបេក គឺខែមេ មើលហ៊ុំកញ្ចូង គឺខែយាំងវិរេ ។

---

ពាក្យពន្យល់.— ប្រក្រតិទិន= រាល់ថ្ងៃ, តារាំងថ្ងៃ, ខែ ។ វាំង= ផ្ទះធំមានកំពែងជុំវិញ ។ ធញ្ញជាតិ= ធម្មជាតិជាមេអាហារ ដូចជាស្រូវ, ពោត, ល្ពៅ, សាលី ។ សក៏ុណៈសត្វ= សត្វស្លាបតូចៗ

ពាក្យសួរ.—១) ប្រក្រតិទិនប្រើការដូចម្តេច ។ ខែទាំងឡាយមានចំនួនប៉ុន្មាន?— ខែអ្វីជាដើម?—(ខែចន្ទគតិ, ខែសុរិយគតិ, ខែបារាំង)— ថ្ងៃទាំងឡាយមានប៉ុន្មានថ្ងៃណាជាដើម (ថ្ងៃអាទិត្យ, បារាំងចន្ទជាដើម) ។ ក្នុងកម្លុងប្រាំពីរថ្ងៃគេហៅថាអ្វី (សត្តាហៈ ឬសប្តាហៈ) ។ ២)— ឃ្មុំជាសត្វនៅក្នុងពួកសត្វអ្វី (ភមរជាតិ) ។ ៣)— សកុណសត្វអ្វីខ្លះដែលអ្នកស្គាល់ ។

---

មជ្ឈិមដ្ឋាន ទី២

## ប្លៃសម្លៀកបំពាក់មួយ

បើអ្នកពោលកន្ទុយកែកទៅលើសម្លៀកបំពាក់មួយ ដែលអ្នកត្រូវផ្គាប់

ពីក្បាលដល់ជើង អ្នកនឹងឃើញថាអ្នកកសិករ ជាងធ្វើអម្បោះ ជាងតម្បាញ ជាងដែក អ្នកនាវិក អ្នកបើកយន្ត ជាងដេរ ជាងដេរស្បែកជើង អ្នកបោកគក់ ជាងធ្វើម្ហូប អ្នកចិញ្ចឹមមាន់ មានឧស្សាហកម្មផ្សេងៗ នៃម្យ៉ាង គេនៅទៀតបានវិចិត្រការជាងក្រមេរ ឬអ្នកប្រាជ្ញបានអនុវត្តពិចារណាទាំងសាកពិសោធតាំងពីហាសិបសតវត្សមកហើយ គេការទាំងធ្វើរបស់សំរាប់ប្រណិតនៃយើងៗ ស្លៀកពាក់ដែលគោលនៃស្បែកជើងអ្នក បំពេញមកអំពីសេចក្តីបើកការ កំណាំងនៃដែក ការកាប់ឈើនៃព្រៃ ការរំលាយនៃរ៉ែគង់ក្នុងប្រទេសធំ ការសំរេច សំពត់ដែលមួយគ្រឿងឲ្យទៅជាដែកស្ងួត ការហូតដែកជាលួស ការធ្វើស្បែក ការធ្វើការដែលដោយហ័សណាស់ ហើយនឹងពីបុរាណធ្វើ ធ្វើដោយដៃ ៗ នៃជាងដែកពាល ។

១) សម្លៀកបំពាក់មានទៀងពីវត្ថុអ្វីខ្លះ ។ ២) ជាងអ្វីខ្លះដែលធ្វើបានជាដែកគោលមួយ ។
៣) សព្វថ្ងៃចម្ដេច = នាវិក - កសិករ - ឧស្សាហកម្ម - វិចិត្រកម្ម - រ៉ែ ។
៤) ចូរសរសេរជាពីរយ៉ាង - កម្រ សំរាំង - រហ័ស ។

## ពស់

ពស់លូនក្នុងព្រៃស្មៅ ឥតមានសូរអ្វីសោះ ដំណើររបស់វាក្រវិកក្រវ៉ក ៗ កាលណាចំណាំងថ្ងៃមកត្រូវ ខ្លួនពស់ភ្លឺឡើងដូចដែកគ្រលើប ប៉ុន្តែបើវាអត់កម្លាំង វាដេកជាវង្វេលហើយសំងំឈឹង ក្នុងវាមានសារធាតុពុលជាគ្រឿងដែលដុះ ។

អ្នកដែលដើរដោយប្រហែស ចូរប្រយ័ត្នទៅទៀបជិតភក់ ទៅលំអក់ ៗ ក់ មាក្អួនខ្លាក់ភក់ចំកជើង ពិសភក់ក៏ផ្សព្វផ្សាយ កើតជាបូសឲ្យមានភ័យឡើង ៗ

កាលណាពស់បានចឹកជើង យើងត្រូវវះត្រង់មុខសាស្ត្រនោះឲ្យឈាមចេញច្រើន ដើម្បីឲ្យពិសចេញទៅតាមឈាម យើងត្រូវអាលមុខរបួសដោយដែកដុតក្រហម ហើយយើងត្រូវប្រញាប់រកគ្រូពេទ្យមកព្យាបាល ៗ

---

ពន្យល់= លង្វែក = បន្ទោះ ។ ផ្សព្វផ្សាយ = រត់សាយទៅពេញខ្លួន ។ មុខសាស្ត្រ= របួស ។

ពាក្យសួរ– ១) កាលណាអ្នកត្រូវរបួសពស់ចឹក អ្នកត្រូវធ្វើដូចម្តេច ។ ២) ពស់មានពិសនោះតើពស់អ្វីខ្លះ ។ ៣) ក្នុងបទវិទ្យាសាស្ត្រ ពស់នៅក្នុងពួកសត្វអ្វី ។ ៤) ចូរស្រង់វណ្ណយុត្តិដែលមានក្នុងពាក្យ ។

---

## មជ្ឈមដ្ឋាន ទី ១

# គ្រឿងអលង្ការយួន

ស្រីៗ ពាក់គ្រឿងអលង្ការ គឺកងក កងដៃ ចំហូ ចិញ្ចៀនមាសឬប្រាក់ ៗ ស្រីចាស់ ៗ ជួនបន្តោកនៅចង្កេះគ្រឿងប្រាក់តូច ៗ គឺត្បាល់បុកស្លា ដែលខ្លួនគ្មានធ្មេញទំពាមិនកើត ៗ ក្មេង ៗ ក៏ពាក់អលង្ការដែរ គឺកងក ៗ ក្មេងតូចទៀតច្រើនពាក់កងជើង ជួនកាលក្មេងតូចពាក់តែកងជើងតែប៉ុណ្ណោះ ជាបម្លែក ព្រោះគេពុំដែលវះតន់ខ្លួនក្មេងស្រាតឡើយ ៗ ជារឿយ ៗ

ក្មេងៗនៅស្រាតរហូតដល់អាយុប្រាំមួយ ឬប្រាំពីរឆ្នាំ ។ ក្មេងប្រុសនៅស្រាតយូរជាងនោះទៅទៀតក៏មាន ។ លុះដល់វាសៀកដណ្ដប់ ក្មេងមានខោអាវចំហាំល្មមនឹងខ្លួន ឬស្លៀកខោតិចដ៏មានពណ៌ស្រស់ចាក់ជាដើម ។ ជួនកាលដាក់ឱនផង ។

---

ពន្យល់ពាក្យ.— អលង្ការ= គ្រឿងតែងខ្លួនធ្វើដោយមាស, ប្រាក់ ឬត្បូង ។ បន្តោក= ព្យួរ ។ ត្បាល់បុកស្លា= បំពង់ស្ពាន់ឬប្រាក់សំរាប់បុកលំអិតម្លូបៀក ។— ឱន=សន្ទឹកស្ពាន់ឬមាសមូលតូចៗ ។

ពាក្យសួរ.— ១) ប្រាប់អ្វីខ្លះដែលគេទុកជាគ្រឿងអលង្ការ ។ ២) ចូររៀបរាប់គ្រឿងអលង្ការយួន គ្រឿងអលង្ការខ្មែរ ។ ៣) សំលៀកបំពាក់ប្លែកគ្នាដូចម្ដេច ខ្មែរ, យួន, ចិន ជ្វា ។ ៤) ទូវនឹងនៅខុសគ្នាដូចម្ដេច ។

---

## អាហារភោជននៃយួន

ពេលព្រលប់ ម្ដាយក្មេងនាំឆ្នាំងធំស្រែប លើកចេញពីជើងក្រាន ហើយដួសដាក់ត្របានតាមមានគ្នាប៉ុន្មានក្នុងគ្រួសារ ។ ចានឯទៀតសំរាប់ដាក់ត្រីហាន់ជាកង់ៗ ដាក់សាច់ចៀន ដាក់បន្លែអន្លក់ ត្រីសក់ ស្ពៃ ស្ពៃក្ដុកបណ្ដុះ ។ល។ គេរៀបបរិភោគដោយចង្កឹះ ចាប់យកអាហារនេះបន្តិចនោះបន្តិច រួចជ្រលក់ក្នុងចានទឹកត្រី ដែលជាគ្រឿងគេរំលងពុំបាន ប្រើជាសម្ល បើគ្មានសម្លទាំងនេះ អាហារភោជនក្នុងប្រទេសនេះមិនបានឡើយ ។ យួនៗមិនប្រើស្លាព្រាសមឡើយ គេកាន់ចង្កឹះយ៉ាងស្ទាត់ ។ តាមទម្លាប់ គេមិនផឹកកំពុងស៊ី គេផឹកនៅចុងកាលបរិភោគវិញ ។

ពាក្យសួរ.— ១) វត្ថុអ្វីខ្លះដែលផ្សំឡើងកើតជាអាហារនៃយើង ។ ២) ជាធម្មតាយើងបរិភោគអាហារប៉ុន្មានដងក្នុងមួយថ្ងៃ ។ ៣) ពួកមនុស្សណាដែលមិនបរិភោគអាហារពេលល្ងាច ។ គ្រឿងភេសជ្ជៈមានអ្វីខ្លះ ។ ៤) ចូរស្រង់ពាក្យដែលសរសេរដោយមានបន្តក់ ។

---

វេយ្យាករណ៍

សុំបង្រៀនក្នុងសៀវភៅវេយ្យាករណ៍ មេរៀនទី ១០

មុខងារនៃអក្សរ

អាទិតដ្ឋាន

## បង្រៀនពាក្យនិងភាសា

អាទិត្យទី១.— អំពីរូបកាយមនុស្ស

### ក្បាល

នាម.— *ក្បាល សក់ មុខ ថ្ងាស់ ភ្នែក ច្រមុះ មាត់ បបូរមាត់ ធ្មេញ ចង្កូម ថ្គាម អណ្តាត ចង្កា ថ្ពាល់ ពុកចង្កា ពុកមាត់ រោមចិញ្ចើម ត្របៀកក ។*

គុណនាម.— *មូល សំប៉ែត កប ខ្មៅ ស ព្រោះ ឥដិត ក្ដី ស្រួច ទាល ធំ តូច ក្រាស់ ស្តើង ជ្រោស ធ្លារ វែង ខ្លី ។*

កិរិយាសព្ទ.— កាត់សក់ លាងក្បាល លុបមុខ ផ្ទៀងត្រចៀកស្ដាប់ ដុសធ្មេញ ជូតថ្ពាល់ ហិតក្លិន ភ្លក់រសជាតិអាហារ កោរពុកមាត់ ពុកចង្កា កាត់ចិញ្ចើម ។

ភាសា.— ក្បាលអ្នកកាន់ដូចម្ដេច? នៅលើក្បាលមានអ្វី? សក់មនុស្សចាស់យ៉ាងដូចម្ដេច? ហៅថាអ្វី? ចុះសក់ក្មេងយ៉ាងដូចម្ដេច? នៅសងខាងក្បាលមានអ្វី? ត្រចៀកសំរាប់ធ្វើអ្វី? ក្បាលភ្ជាប់ទៅដងខ្លួននឹងអ្វី? យើងស្គាល់របស់ល្អអាក្រក់ដោយសារអ្វី? ឯងដឹងក្លិនក្រអូបស្អុយដោយសារអ្វី? នៅក្នុងមាត់មានអ្វីខ្លះ ។ល។

ការហាត់សរសេរ.— ចូរធ្វើឃ្លានឹងពាក្យមួយម៉ាត់ៗ ខាងក្រោមនេះ ក្បាល ។ ភ្នែក ។ ច្រមុះ ។ ត្រចៀក ។

## បង្រៀនមើល

### អំពីខ្លួនមនុស្ស

*សៀវភៅវត្ថុស្គាល់ផ្សាយទំនាក់ទំនង ទំព័រ ៥*

អានពាក្យ.— អង្គុស្ថលិក = អ័តង៉ុសន់ខៈ លិកៈ ។

អរិយវិ = អៈ រិៈ យៈ វិៈ ។

ដម្រៃពាក្យ.— ភោ = ភោជ ។ ទេ = ទ្វេ ។ សុគតៃ = សុខ្វៃ

ហាត់ភាសា.— ខ្លួនមនុស្សមានប៉ុន្មានចំណែក? គឺអ្វីខ្លះ? នៅក្បាលខាងមុខមានអ្វីខ្លះ? ប្រមុះបារាំងស្រួចឬទាល? ចុះប្រមុះខ្មែរ? មនុស្សកខ្លីគេហៅថាអ្វី? ចុះមនុស្សកវែងហៅថាអ្វី? ។ ផ្ទៃលលាដ៍ក្បាលរាងដូចម្ដេច? មានសណ្ឋានដូចអ្វី? មាត់យើងមានថ្គាមប៉ុន្មាន? នៅលើថ្គាមមានអ្វី? ថ្គាមលើនិងថ្គាមក្រោមខុសគ្នាដូចម្ដេច? ។

## សរសេរតាមសូត្រ

### អំពីក្បាល

ខ្លួនមនុស្សមានបីចំណែក គឺក្បាល-ដងខ្លួនហើយនិងដៃជើង ក្បាលរាងមូល នៅលើក្បាលមានសក់ សក់មនុស្សក្មេងខ្មៅ សក់មនុស្សចាស់សគឺសក់ស្កូវ ។ នៅមុខមានភ្នែកពីរសំរាប់មើល ។ មនុស្សក្មេងភ្នែកភ្លឺមើលឃើញច្បាស់ ប្រមុះមានរន្ធពីរសំរាប់ដកដង្ហើម ។ ខាងក្រោមប្រមុះមានមាត់និងបបូរមាត់ពីរ ។ កាលណាគេហាមាត់គេមើលឃើញធ្មេញហើយនិងអណ្ដាត ។ អណ្ដាតសំរាប់និយាយ ។ ខាងក្រោមមាត់មានចង្កា នៅសងខាងចង្កាមានថ្ពាល់ ។ មនុស្សប្រុសមានពុកដុះនៅបបូរមាត់លើ នៅថ្ពាល់ហើយនិងចង្កា គឺជាពុកមាត់ ពុកចង្កា ។ល។—

សរសេរពាក្យពិបាក.— -រន្ធ-បបូរមាត់-ថ្ពាល់-ចង្កា-អណ្ដាត

## តែងសេចក្ដី

ចូរអធិប្បាយអំពីរូបរាងកាយមិត្តសំឡាញ់របស់អ្នក ។

១– សេចក្ដីផ្ដើម.– មិត្តសំឡាញ់អ្នកឈ្មោះអ្វី-នៅរៀនសូត្រឯណា?

២– សេចក្ដីរៀបរាប់.– អំពីក្បាល-មុខ-មាត់-និងខ្លួនដៃជើង កំពស់ ។

៣– សេចក្ដីបញ្ចប់.– អំពីកិរិយាមារយាទ សំលៀកបំពាក់និងយោបល់យល់ឃើញរបស់អ្នក ។

## អក្សរផ្ចង់

*ខ ខ៊ ខ៉ ខ៊ ខ៍*

*ខ ខា ខី ខូ ខួ ខើ ខឿ ខៀ ខេ ខែ ខៃ ខោ*

*គេខុសកុំអាលអរ គេសាទរកុំអាលអួត ។*

## បង្រៀនពាក្យនិងភាសា

*អាទិត្យទី ២.–* **អំពីដងខ្លួន**

នាម.– *ទ្រូង ពោះ ផ្ចិត ខ្នង ចង្កេះ ត្រគាក ស្មា ។ សួត បេះដូង ថ្លើម ប្រមាត់ ក្រពះអាហារ ពោះវៀន ឈាម ។*

គុណនាម.— ពើង ប៉ោង ផត ធំ ទូលាយ គោង ស្វិត វែង ខ្លី ខ្វង់ ក្រហម លឿង រឹង ។

កិរិយាសព្ទ.— ស្ងួតទ្រូង ឈឺពោះ ពោយចង្កេះ ពត់ចង្កេះ ដកដង្ហើមចេញ ដកដង្ហើមចូល ឈាមរត់ ជូសស្មា ។ ល ។

ហាត់ភាសា.— ឯណាដងខ្លួន? ដែលហៅថាដងខ្លួនពីត្រឹមណាទៅ ដល់ត្រឹមណា? នៅដងខ្លួនមានអ្វីខ្លះ? ទ្រូងនៅខាងមុខឬខាងក្រោយ? ពោះនៅត្រង់ណា? នៅលើពោះមានអ្វី? ខាងក្រោយដងខ្លួនហៅអ្វី? នៅក្នុងទ្រូងមានអ្វីខ្លះ? នៅក្នុងពោះមានអ្វី? សួតសំរាប់ធ្វើអ្វី? ចុះបេះដូងសំរាប់ធ្វើអ្វី? ។

ការហាត់.— ចូរបំពេញឃ្លានៅក្នុងចន្លោះខាងក្រោមនេះ ក្បាលជាប់ទៅ.....នឹងក ។ បំណែកខាងលើដងខ្លួនមាន......បំណែកខាងក្រោមមាន...... ខាងក្រោយមាន... ។ ក្នុងទ្រូងមាន... សំរាប់ដកដង្ហើមមាន.... សំរាប់បង្ហូរឈាម ។ ក្នុងពោះមាន....ហើយនិង...ដែលជាគ្រឿងប្រដាប់សំរាប់រំលាយអាហារ ។

## បង្រៀនមើល

### អដ្ឋិសង្ខលិក-ដងខ្លួន

សៀវភៅវគ្គស្វាធ្យាយបឋមញ្ញាណដ្ឋាន ទំព័រ ៦

ភាសា.— ដងខ្លួនមនុស្សយើងមានឆ្អឹងអ្វីខ្លះ? ឆ្អឹងខ្នងបែបដូចអ្វី? កង់វាដូចម្ដេច? ឆ្អឹងជំនីរកោងដូចម្ដេច? ឆ្អឹងជំនីរមានប៉ុន្មានគូ? ឆ្អឹងជំនីរមកពីណាទៅជាប់និងអ្វី? ឆ្អឹងខ្នងឆ្អឹងទ្រូងឆ្អឹងជំនីររួមទៅបានជាអ្វី? ហៅថាអ្វី? ក្នុងទ្រូងមានអ្វី? ទ្រូងសំរាប់ធ្វើអ្វី? ។

## តែងសេចក្ដី

ចូរអធិប្បាយ អំពីមិត្តសំឡាញ់អ្នកម្នាក់ រត់ទាត់សីដួលបាក់ដៃម្ខាង អ្នកបានឃើញឆ្អឹងដូចម្ដេចខ្លះ រួចគ្រូពេទ្យបានធ្វើដូចម្ដេចខ្លះ អ្នកយល់ឃើញដូចម្ដេចខ្លះ ។

## សរសេរតាមសូត្រ

### អំពីដងខ្លួន

ក្បាលជាប់ទៅដងខ្លួនដោយក ។ ចំណែកខាងលើដងខ្លួនមានទ្រូងខាងក្រោមមានពោះ ខាងក្រោយមានខ្នង ។ ក្នុងទ្រូងមានសួតសំរាប់ដកដង្ហើម មានបេះដូងសំរាប់បង្ហូរឈាម មានថ្លើមសំរាប់បញ្ចេញទឹកប្រមាត់ ។ ក្នុងពោះមានក្រពះផាយ ហើយនិងពោះវៀន ដែលជាគ្រឿងប្រដាប់សំរាប់រំលាយអាហារ ខាងក្រោមពោះមានផ្លោកនោម សំរាប់ទទួលទឹកនោមមកពីអន្តញ់បង្កោះដែលនៅខាងក្រោមខ្នង ។ ទឹកនោមចេញតាមទ្វារតូច ។

សរសេរពាក្យពិបាក.— ក — ពោះ — បេះដូង — បង្ហូរ — បញ្ចេញ — ផ្លោក អន្តញ់ — បង្កោះ ។

## អក្សរផ្ចង់

ខ ខ្ញ ខ្ញ ខ្ញ ខ្ញ

ខឹងខុស ខុសខូច ខូចខាត ខ្ញកញ៉ា ខ្ញៀខ្ញៀក ខ្ញុំ

( ត្រូវសរសេរអក្សរធំមួយបន្ទាត់ កណ្ដាលមួយបន្ទាត់ តូចមួយបន្ទាត់ )

## បង្រៀនពាក្យនិងភាសា

អាទិត្យទី ៣ ដៃជើង ( អវយវលើ )

នាម.— ដើមដៃ កែងដៃ កំភួនដៃ កដៃ ដៃ បាតដៃ ខ្នងដៃ ក្រចក ម្រាមដៃ ចង្អុលដៃ ម្រាមកណ្ដាល នាងដៃ កូនដៃ ។

គុណនាម.— តូច ធំ វែង ខ្លី ស្រួច ស្គួច រឹង សំប៉ែត ស្ដាំ ឆ្វេង

កិរិយាសព្ទ.— លាដៃ បត់ដៃ ពារដៃ ចាប់ដៃ កាត់ក្រចក លើកដៃ ចងដៃ ក្រពន្ធដៃ ។

ភាសា.— យើងមានដៃប៉ុន្មាន ? ឯណាដៃស្ដាំ - ឆ្វេង ? ដៃនិមួយ ៗ មានប៉ុន្មានកំណាក ? ដើមដៃនិងកំភួនដៃខណ្ឌនាងនឹងអ្វី ? ដៃមួយៗមានម្រាមប៉ុន្មាន ? ម្រាមដៃទាំងប្រាំនេះឈ្មោះដូចគ្នាឬទេ ? អ្នកស្គាល់ឈ្មោះម្រាមដៃទាំងប្រាំនេះឬទេ ? ដៃសំរាប់ធ្វើអ្វី ? មេដៃខុសពីម្រាមឯទៀតបានឬទេ ? កូនដៃគេសំរាប់ធ្វើអ្វី ? ។

## បង្រៀនមើល

### អង្គីសង្គលិក អរិយវិលើ

សៀវភៅដដែលទំព័រ ៨ ។

កែជម្រើវពាក្យ.— ផ្ជាប់ = ភ្ជាប់ ។ កំប៉ិត = កាំបិត ។ ករ = ក ។ បាទដៃ = បាតដៃ ។

(សូមមេទេសួរបំបែកប្រាជ្ញាសិស្សខ្លួនអាទិត្យមុនៗ) ។

## សរសេរតាមសូត្រ

### អំពីដៃជើង (អរិយវិលើ)

មនុស្សយើងមានដៃពីរ គឺដៃស្តាំនិងដៃឆ្វេង ។ ដៃជាប់នៅនឹងខ្លួនតាមស្មា ហើយនិងឆ្អឹងផងកាំបិត ។ ដៃមានបីចំណែក គឺដើមដៃ កំភួនដៃ ហើយនិងគូដៃ ។ ដើមដៃជាប់នៅកំភួនដៃនិងកែងដៃ កំភួនដៃជាប់នៅគូដៃនិងកដៃ ។ គូដៃមានម្រាមប្រាំ គឺមេដៃ ចង្អុលដៃ ម្រាមកណ្ដាល-នាងដៃ ហើយនិងកូនដៃ ។ គូដៃមានខ្នងដៃហើយនិងបាតដៃ ។ នៅចុងម្រាមដៃនិមួយៗ មានក្រចក ។ ដៃសំរាប់ចាប់ហើយនិងកាន់របស់ទាំងឡាយ ។៚—

សរសេរពាក្យពិបាក.— កាំបិត ។ ម្រាមប្រាំ ។ បាតដៃ ។ របស់ ។ ចង្អុល ។

## តែងសេចក្ដី ១

ចូរតែងសេចក្ដីជាឃ្លា ៗ នឹងពាក្យខាងក្រោមនេះ

ដៃ ។ ម្រាមដៃ ។ កំភួនដៃ ។ ខាងដៃ ។ កែងដៃ ។

## អក្សរផ្ចង់

សុំឲ្យដាក់តួអក្សរឲ្យសិស្សសរសេរដូចអាទិត្យមុន ។

## បង្រៀនពាក្យនឹងភាសា

### អាទិត្យទី ៤ — អំពីដៃជើង (អវយវក្រោម)

នាម.— ជើង ភ្លៅ ជង្គង់ កំភួនជើង ស្មងជើង កជើង ក្រួកគោរ ម្រាមជើង បាតជើង កែងជើង ។

គុណនាម.— ធំ មាំ ខ្លាំង ហើម លឿន វែង ខ្លី ធ្ងន់ ស្រាល ។

កិរិយាសព្ទ.— ដើរ រត់ លោត ជ្មោះ ទាត់ ធាក់ រើតជើង អង្គុយ លុតជង្គង់ ។

ភាសា.— អ្វីដែលទ្រទ្រង់ខ្លួនយើង? ជើងជាប់នៅខ្លួននឹងអ្វី? ជើងនិមួយ ៗ មានប៉ុន្មានចំណែក? គឺអ្វីខ្លះ? កន្លែងដែលខណ្ឌភ្លៅនឹងកំភួនជើងហៅថាអ្វី? ម្រាមជើងនឹងម្រាមដៃខុសគ្នាដូចម្ដេចខ្លះ? ពីព្រោះអ្វីបានជាម្រាមដៃវែងជាងម្រាមជើង? ។

ការហាត់.— ចូរឆ្លើយឲ្យប្រកបនឹងពាក្យសួរខាងក្រោមនេះ - ជើងសំរាប់ធ្វើអ្វី? - ជើងនិមួយៗមានប៉ុន្មានចំណែក? - គឺអ្វីខ្លះ? - ស្មងជើងនៅត្រង់ណា? - ជើងភ្ជាប់ទៅខ្លួននឹងអ្វី? - កន្លែងដែលខណ្ឌភ្លៅនិងកំភួនជើងហៅថាអ្វី?

## បង្រៀនមើល

### អដ្ឋិសង្ខលិក - អវយវៈក្រោម (ត)

សៀវភៅ ដែលទំព័រ ៨-៩

## សរសេរតាមសូត្រ

### អំពីជើងដៃ (ត) អវយវៈក្រោម

យើងមានជើងពីរសំរាប់ដើរ រត់ លោត ។ ជើងនិមួយៗមានភ្លៅមួយ ដែលមានស្មងនៅខាងមុខ កំភួនជើងនៅខាងក្រោយ ហើយនឹងគូជើងនៅខាងចុង ។ ភ្លៅភ្ជាប់ទៅស្មងនឹងជង្គង់ ហើយនឹងក្បាលជង្គង់ ។ ស្មងភ្ជាប់ទៅគូជើងនឹងកជើង ហើយនឹងកែងកោរ ។ គូជើងមានម្រាមប្រាំដូចជាដៃដែរ ហើយមានក្រចកជើងនឹងបាតជើងដែរ ប៉ុន្តែម្រាមជើងខ្លីជាងម្រាមដៃ ហើយចាប់កាន់អ្វីពុំបាន ។

សរសេរពាក្យពិបាក.— ពីរ ។ ភ្លៅ ។ ជង្គង់ ។

# តែងសេចក្ដី

ជីតាអ្នកគាត់ចាស់ជរា ចូរអ្នកអធិប្បាយអំពីកិច្ចការៈដែលអ្នកបានធ្វើ បានគោរពនឹងជីតាអ្នកនោះ តើដូចម្ដេចខ្លះ ?

## សេចក្ដីអធិប្បាយជាគំរូ

ជីតាខាងឪពុកខ្ញុំបាទ គាត់រស់នៅសព្វថ្ងៃ ប៉ុន្តែគាត់ចាស់ជរាណាស់ ហើយ អាយុគាត់ ៨៤ ឆ្នាំ សក់ស្កូវ ធ្មេញបាក់ ស្បែក យុល យារ ជ្រួញជ្រីវ ថ្ពាល់ខ្ទង់ ខ្នងកោង ដើរបានតែនឹងឈើច្រត់ ភ្នែកងងឹត លុះតែពាក់វ៉ែនតា ទើបមើលឃើញ ។

ខ្ញុំបាទស្រឡាញ់ អាណិតជីតាខ្ញុំពន់ពេកណាស់ ។ រាល់ថ្ងៃខ្ញុំបាទបំរើគាត់មិនមានធុញថប់អ្វីសោះ គឺដងទឹកជូនគាត់ងូត លើកបាយទឹកជូនគាត់ពិសា រៀបចំបោសសំអាតដំណេកជូនគាត់សំរាន្ត ។ កាលណាជីតាខ្ញុំបាទចង់ដើរលេង ខ្ញុំជូនគាត់ដើរលេងតាមចំណង់ចិត្ត ។

នៅវេលាយប់ ឬ ថ្ងៃសិល ជួនណាជីតាខ្ញុំនិយាយរឿងព្រេងដ៏ពីរោះ ប្លែកៗ ឲ្យខ្ញុំបាទស្ដាប់ ជួនណាគាត់ទូន្មានឲ្យខ្ញុំបាទខំរៀនសូត្រ និងប្រព្រឹត្តកិរិយាល្អ នោះខ្ញុំបាទក៏ខំប្រតិបត្តិតាមសេចក្ដីទូន្មានជីតាខ្ញុំ ហើយខ្ញុំបាទក៏រឹតតែមានសេចក្ដីស្នេហា និងអាណិតអាសូរគាត់ដែលចាស់ជរាពេកណាស់ ។ ខ្ញុំបាទបន់ឲ្យតែជីតាខ្ញុំបាទពិសាបាន សំរាន្តស្រួល ឲ្យរស់នៅបានយូរអង្វែងតទៅ ។

អាទិកដ្ឋាន

# នព្វន្ត

## អាទិត្យទី ១.— លេខចែកចំនួនធំ

### លេខដើងហារមានតែលេខមួយតួ

(មើលក្នុងក្បួននព្វន្តអាទិកដ្ឋានទំព័រទី ៤៧)

ដូចជា: ៤៣ : ៩ =

### វិធីហាត់គិតមាត់ទទេ

សុំសួរមេគុណពី ៦, ៧, ៨, ៩, ឡើង

### វិធីហាត់សរសេរ

៤៩ : ៧ = ..... ៤៨ : ៦ = ..... ៥៦ : ៧ = .....

៥៦ : ៨ = ..... ៣៦ : ៩ = ..... ៦៣ : ៩ = .....

## អាទិត្យទី ២.— លេខគុណនឹងចំនួនធំ

### មេគុណមានលេខពីរតួ

ឯរបៀបសុំមើលតាមក្បួននព្វន្តដដែលទំព័រ ៩២

### វិធីហាត់សរសេរ

| | | | |
|---|---|---|---|
| ២៣៥ ម | ១៩៥ រ | ២៣៩ ម | ៣១៦ ម |
| × ២១ | × ១៧ | × ៣២ | × ៤២ |

សុំគ្រូដាក់ចំណោទឲ្យសិស្សធ្វើផង

## អាទិត្យទី ៣.— លេខចែកចំនួនធំ

### លេខជើងហារមានលេខពីរខ្ទង់

(មើលក្នុងក្បួនគណិតដែលទំព័រទី ៩៩)

### វិធីហាត់សរសេរ

២៨៨ : ២៥= ....... ២២៥ : ៤ = ....... ២៦៩ : ៣៤=

២៦៩៥ : ៣៤= ....... ៤៦៤១ : ៥២= .......

### បំណោទ

ឪពុកខ្ញុំមានប្រាក់ ៦៧៨៧ រៀល គាត់ទុកសំរាប់ធ្វើបុណ្យខ្លួនគាត់ ហើយសល់ប៉ុន្មានគាត់ចែកទៅឲ្យកូនគាត់ ៧ នាក់ តើកូនម្នាក់ៗ បានប្រាក់ប៉ុន្មាន ។

## អាទិត្យទី៤.— របៀបលេខគុណ ហើយនឹងលេខចែកនឹងមេ

១០, ១០០, ១០០០, ៗ

(សុំមើលក្នុងក្បួនគណិតដែលទំព័រទី ៦៣)

ដូចជា ១២ × ១០ = ១២០

ធ្វើលេខនេ នៅលើក្តារខៀនឲ្យសិស្សមើលរួចប្រាប់ថាលេខបែបនេះគេមិនចាំបាច់ធ្វើទេ គេបន្ថែមតែសូន្យនៅខាងស្តាំបានហើយ បើគុណនឹង១០ត្រូវថែមសូន្យមួយ បើគុណនឹង១០០ត្រូវថែមសូន្យពីរ— ល។

*សូត្រមេគុណសាឡើងវិញមេ ៦,៧,*

**រង្វាស់រង្វាល់**

## អាទិត្យទី ១.— គីឡូម៉ែត្រ-គីឡូក្រាម

សុំធ្វើរូបជាបន្ទៀត ហិកតូម៉ែត្រ ហិកតូក្រាម

*អាទិត្យទី២.—* អំពីកាំងតាស់-តោន

(មើលក្នុងក្បួនគណិតអាទិកដ្ឋានទំព័រទី៦៤-៦៥)

*អាទិត្យទី៣.—* រង្វាស់រង្វាល់ខ្មែរ

អំពីបំណុះ ហ៊ឹង-តៅ-កន្តាំង

(មើលក្នុងសៀវភៅនគរបាលនៅទំព័រទី ១៥)

*អាទិត្យទី៤.—* សុំសាបជ្រៀនពីអាទិត្យទី១-២-៣ឡើងវិញ ។

ហើយដាក់ការហាត់សរសេរឲ្យសិស្សធ្វើ ។

---

## នព្វន្ត

កុមារដ្ឋាន

*ចំនួនពី ៥០ ដល់ ៧០*

- រាប់ពី ១ ដល់ ៧០ ចុះមក ១ វិញ ។
- បន្ថែម ឬ បន្ថយ ២ ម្តង, ៣ ម្តង, ៤ ម្តង ។
- លេខបូកនឹងលេខសង ដែលមានលេខពីរខ្ទង់ ហើយមានត្រាទុក ។
- មតិសំខាន់ = រាប់បន្ថែមម្តង ៤, បន្ថយម្តង ៤ ។

*មតិសំខាន់.—* គ្រូប្រាប់ឲ្យសិស្សរាប់ពី ១ ដល់ ៥០.

១)— បន្ថែមម្តង ៤ ចាប់ពី ១ ទៅ = ៥; ៩; ១៣; ១៧; ២១; ២៥; ២៩; ៤៣; ៤៧; ។

២)— បន្ថយម្តង ៤ ចុះពី ៥០ មក = ៤៦; ៤២; ៣៨; ៣៤; ៣០; ២៦; ២២; ១៨; ១៤; ១០; ៦; ២; ។

**មេរៀន.—** ចំនួនពី ៥១ ដល់ ៧០.

រៀនផ្សំចំនួន - រៀនសរសេរលេខ - រៀនមើលលេខ -

**លេខ៥០.—** ១)— គ្រូបង្ហាញបង្កើះ ៤ បាច់ (១ បាច់ ១០) ហើយនឹងបង្កើះរាយ ៩ ។ ហើយសួរសិស្សថា: បង្កើះទាំងអស់ប៉ុន្មាន ? សិស្សឆ្លើយថា ៤៩ ។

២)— គ្រូបន្ថែមបង្កើះ១ទៅក្នុងពួកបង្កើះរាយ ៩ បានជាបង្កើះ៤០ ហើយនឹង១០ ។

៣)— គ្រូប្រាប់សិស្សថា: ៤០ ហើយនឹង ១០ ត្រូវជាបង្កើះ ៥០ ឬដប់ប្រាំដងឬ ៥០ ។

៤)— សិស្សប្រើពាក្យថា: ហាសិប ។

៥)— គ្រូសរសេរចំនួន ៥០ នោះនៅក្ដារខៀនឲ្យសិស្សសរសេរតាមនៅក្ដារជ្នួន ។

៦)— គ្រូបែងចំនួន ៥០ នោះដូចខាងក្រោមនេះ = ៥០ = ១០ + ១០ + ១០ + ១០ + ១០ = ៥ បាច់ ។ បង្កើះ ១០ ។ លេខ ០ សំគាល់ថាគ្មានបង្កើះរាយ ។

**លេខ ៥១** វិធីហាត់នឹងបង្កើះ

១)— ចៅកៅឯងយកបង្កើះ ៥ បាច់មកកាន់បង្ហាញឲ្យគេមើល ។

២)— ចៅពេជ្រឯងឃើញចៅកៅកាន់បង្កើះប៉ុន្មានបាច់ ? តើបង្កើះទាំងអស់មានប៉ុន្មាន ?

៣)— គន្ធ្រ យកបង្កើះ ១ រាយមកថែមលើបង្កើះ ៥០ ដែលកៅកាន់ ។

៤)— សុខ - តើកៅកាន់បង្កើះទាំងអស់ប៉ុន្មាន ? (ទាំងអស់មានបង្កើះ ១០ ប្រាំដង នឹងបង្កើះ ១ រាយ ឬ ៥១) ។

៥)— គ្រូសរសេរលេខ ៥១ នៅក្ដារខៀន - ឲ្យសិស្សមើល ហើយសរសេរតាម ។

**លេខរៀងក្រៅទៀត.—** លេខ ៦០ នឹង ៧០ រៀនដូច ៥០ លេខ ៥២ រហូតដល់ ៦៩ រៀនដូច ៥១

**វិធីហាត់សរសេរនិងហាត់មាត់ទទេ.—**

១)— ឲ្យសិស្សថាចំនួននេះ= ៥២, ៦៣; ៧០; ៥៥; ៦១; ៥៩ ។

២)— ឲ្យសិស្សរាប់ពី ៥០ ឡើងទៅដល់ ៧០ បន្ថែមម្ដង ២, ម្ដង ៣, ម្ដង ៤, ចុះពី ៧០ មក ៥០ បន្ថយម្ដង ២, ម្ដង ៣; ម្ដង ៤ ។

៣)– ឲ្យសិស្សមើលចំនួនទ្វេលេខនេះ= ១១ (២២); ៣៥ (៧០); ២៥ (៥០); ១៨ (៣៦); ១៥ (៣០) ។

៤)– ឲ្យសិស្សថាចំនួនពាក់កណ្ដាលលេខនេះ= ៧០ (៣៥); ៥០ (២៥) ២៨ (១៤); ៦ (៣); ១០ (៥) ។

---

## លេខបូកនិងលេខសងដែលមានលេខពីរខ្ទង់ហើយនិងត្រាទុក

**លេខបូក.–** ខ្ញុំបូក ២៧ សេន និង ១៥ សេន

១)– ខ្ញុំធ្វើលេខដោយមតិសំខ្យា=

២៧+១៥=៤២ ខ្ញុំថា= ២៧ និង ១០ ត្រូវជា= ៣៧; ៣៧ បូកនឹង ៥ ត្រូវជា= ៤២ ។

២)– ខ្ញុំធ្វើលេខដោយសរសេរ

$$\begin{array}{r} +២៧ \\ ១៥ \\ \hline ៤២ \end{array}$$

ខ្ញុំថា= ៧ និង ៥ ត្រូវជា ១២ ឬ ១ មួយដងនឹង ២ រាយ ។ ខ្ញុំសរសេរលេខ ២ រាយ នៅក្រោមខ្ទង់រាយ ហើយខ្ញុំត្រាទុក១ (ខ្ទង់ដប់) ។ ខ្ញុំបូកលេខខ្ទង់ដប់ ។ ខ្ញុំថា ១ (ដែលខ្ញុំត្រាទុក)បូកនឹង ២ ត្រូវជា ៣; ៣និង១ត្រូវជា៤; ទាំងអស់ត្រូវជា ៤២ ។

**លេខសង–** ខ្ញុំដក ២៧ ពី ៤៥ ឬយក ២៧ ទៅសង ៤៥ ខ្ញុំមានបង្គោះ ៤៥ ឬ HHHH IIIII

ខ្ញុំមានបង្គោះ ២៧ ឬ H H II IIIII

ដើម្បីនឹងដក ៧ ពីចំនួនលើ ខ្ញុំត្រូវស្រាយបង្គោះ១ បាច់ទៀត ។

ឥឡូវនេះខ្ញុំមានបង្គោះ ៤៥ ឬ HHH IIIIIIIIII IIIII

–"– ២៧ ឬ HH II IIIII

ខ្ញុំដក ៧ ពី ១៥ នៅសល់ ៨; កាលមុនខ្ញុំបានស្រាយបង្គោះ ១បាច់ គឺខ្ញុំដក ១ ពី ៤ ខ្ទង់ដប់ ។ ឥឡូវខ្ញុំដក ២ទៀត; ត្រូវជា ៣; ៤ ដក ៣ បេញនៅសល់ ១ ។

ខ្ញុំបានជាលេខ –៤៥ ឬ H IIIIIIII

២៧

១៨ H IIIIIIII

**វិធីហាត់សរសេរ.–** ១៥+៨= ; ៣២+១៨= ; ៤៣+៨= ;

៥២ –៤៦= ; ៤៥–២៩= ;

ខ្ញុំទៅផ្សារមានប្រាក់ ២៦៛ ។ ខ្ញុំទិញត្រីអស់ ៨៛ បន្លែអស់ ៥៛ និងសាច់ជ្រូកអស់ ៧៛ ។ តើខ្ញុំចាយអស់ប៉ុន្មាន ហើយនៅសល់ប្រាក់ប៉ុន្មានមកផ្ទះវិញ ? ។

# រង្វាស់រង្វាល់

## កុមារដ្ឋាន

## គីឡូក្រាម - ប្រយោជន៍នៃគីឡូក្រាម
## ហិកតូក្រាម - ដេកាក្រាម - ក្រាម

*គីឡូក្រាមជាកូនជញ្ជីង សំរាប់ថ្លឹងទម្ងន់វត្ថុទាំងពួង ដូចជាសណ្តែក អង្ករ - ម្រេច - ម្សៅ - ដែក - សាច់ លោហធាតុផ្សេងៗ ។*

*ក.— វិធីពិនិត្យកូនជញ្ជីង ទម្ងន់ ១ គីឡូក្រាម.—*

១)— គ្រូលើកគីឡូក្រាមប្រាប់សិស្ស ហើយថានេះកូនជញ្ជីងទម្ងន់១គីឡូក្រាម ។

២)— គ្រូឲ្យសិស្សថាឈ្មោះទម្ងន់នោះ ច្រើនគ្នា ។

៣)— គ្រូសរសេរ គីឡូក្រាមនៅក្តារខៀន ។ សរសេរគ្រប់តួអក្សរ (គីឡូក្រាម) និងសរសេរកាត់ (គ. ក្រ.) ។

៤)— គ្រូសួរសិស្សឲ្យរកបែបផែនរាង, ពណ៌, ជាតិ, លោហធាតុ, អក្សរ, បាតលើ, បាតក្រោម ។

៥)— គ្រូឲ្យសិស្សកាន់យួរ, ស្ទួយ, ទ្រ ទម្ងន់គីឡូក្រាមនោះ ហើយឲ្យសិស្សបេះតាំ ប្រមាណថា: ប៉ុណ្ណោះទម្ងន់១ គីឡូក្រាម ។

៦)— គ្រូយកជញ្ជីង-គីឡូក្រាម និងវត្ថុអ្វីមួយដូចជាដែកគោល មកថ្លឹងបង្ហាញរបៀបថ្លឹងឲ្យសិស្សបានដឹងផង ហើយប្រាប់សិស្សថា នេះដែកគោល ទម្ងន់ ១ គីឡូក្រាម ។

៧)— គ្រូឲ្យសិស្ស លើក កាន់យួរ កញ្ចប់ដែកគោលទម្ងន់ ១ គីឡូក្រាម នោះ មើលប្រមាណម្តងទៀត ។

## ខ)– វិធីស្មានទម្ងន់វត្ថុដោយគ្មានថ្លឹង.–

១)– គ្រូឲ្យកូនជញ្ជីង ១ គីឡូក្រាម និងដីខ្សាច់ ១ ប្រអប់ទៅសិស្ស ហើយឲ្យសិស្សស្មានមើលទម្ងន់ដីខ្សាច់នោះ ដៃម្ខាងកាន់គីឡូក្រាម ដៃម្ខាងកាន់ប្រអប់ខ្សាច់ ។

២)– សិស្សស្មានទម្ងន់ខ្សាច់ហើយកត់ត្រាទុកនៅលើក្ដារឆ្នួនលើកជូនគ្រូមើល ។

៣)– គ្រូហៅសិស្សម្នាក់ ឲ្យទៅថ្លឹងទម្ងន់ខ្សាច់នោះ ឲ្យបានដឹងទម្ងន់ជាក់ច្បាស់ ។ ឃើញទម្ងន់ប៉ុន្មាន ។ គ្រូត្រួតមើលចម្លើយសិស្ស តើសិស្សណាបេះស្មានត្រូវ។

៤)– គ្រូឲ្យសិស្សស្មានទម្ងន់វត្ថុអ្វី ១ ទៀតដូចជាដុំថ្ម ។ ម្ដងនេះមិនឲ្យសិស្សកាន់គីឡូក្រាមដូចមុនទៀតទេ ។

៥)– រួចហើយ ថ្លឹងពិនិត្យមើលទម្ងន់ដូចរបៀបមុន ។

## គ) វិធីហាត់សរសេរ.–

៨ គ.ក្រ + ៣ គ.ក្រ =; ២ គ.ក្រ + ២៨ គ.ក្រ =:
១៥ គ.ក្រ – ៧ គ.ក្រ= ៣៣ គ.ក្រ– ១៩ គ.ក្រ= ។

ខ្ញុំទិញសាច់ជ្រូកម្ដង ៨ គ.ក្រ ។ ម្ដងទៀត ១៣ គ.ក្រ ។ ខ្ញុំយកទៅស្ល អស់ ៥ គ.ក្រ ។ តើខ្ញុំទិញសាច់ជ្រូកទាំងអស់ប៉ុន្មានគីឡូក្រាម ហើយខ្ញុំនៅសល់ប៉ុន្មានគីឡូក្រាមទៀត ? ។

**ហិគ្តូក្រាម.–** បង្រៀនដូចគីឡូក្រាម ។ បង្ហាញសិស្សឲ្យដឹងថា= ហិគ្តូក្រាមតូចជាងគីឡូក្រាម ១០ដង ឬ ១ គ.ក្រ= ១០ ហ.ក្រ ។

**ដេកាក្រាម=** បង្រៀនដូចគីឡូក្រាម ។ បង្ហាញសិស្សឲ្យដឹងថា= ដេកាក្រាម តូចជាងគីឡូក្រាម= ១០០ ដង តូចជាង ហិគ្តូក្រាម ១០ដង

ឬ ១ គ.ក្រ= ១០០ ដ.ក្រ.

១ ហ.ក្រ= ១០ ដ.ក្រ.

ក្រាម.— បង្រៀនដូច គីឡូក្រាម ។ បង្ហាញសិស្សឲ្យដឹងថា =

ក្រាម តូចជាង គីឡូក្រាម = ១០០០ ដង

„ ហិកតូក្រាម = ១០០ „

„ ដេកាក្រាម = ១០ „

ឬ ១ គ. ក្រ = ១០០០ ក្រ

១ ហ. ក្រ = ១០០ ក្រ

១ ដា. ក្រ = ១០ ក្រ

| គីឡូក្រាម | ហិកតូក្រាម | ដេកាក្រាម | ក្រាម | |
|---|---|---|---|---|
| ១ → | | | | បំបែកជា គ. ក្រ |
| ១ | ០ → | | | បំបែកជា ហ. ក្រ |
| ១ | ០ | ០ → | | បំបែកជា ដា. ក្រ |
| ១ | ០ | ០ | ០ → | បំបែកជាក្រាម |

អាទិកដ្ឋាន

វត្ថុស្វាធ្យាយន៍

មេរៀនទី១ — អង្គភាពនឹងអង្គការនៃរុក្ខជាតិ

ការពិនិត្យ— បង្គាប់សិស្សឲ្យយកគ្រាប់ឈើផ្សេងៗ មកបណ្ដុះក្នុង បំពង់ឫស្សី ឬក្នុងប្រអប់ ឬក្នុងដីណាមួយឲ្យត្រូវខ្យល់នឹងចំហាយថ្ងៃ ហើយស្រោចទឹកឲ្យស្រួលល្មមដុះបាន ។ ដល់ពេលបង្រៀននាំសិស្សពិនិត្យអង្កេតនៃគ្រាប់ដែលពន្លកដុះនោះ គ្រាប់ខ្លះកង់មូល (កប់ឈ្មោះ) គ្រាប់ខ្លះកង់ទ្រវែង (កប់ឈ្មោះ) គ្រាប់ខ្លះតូចៗ (គ្រាប់ល្ហុង ត្របែក) គ្រាប់ខ្លះធំ (គ្រាប់ស្វាយ-ខ្នុរ) ។ ឲ្យស្ទាបមើលគ្រាប់ ក៏ហើមប៉ោងឡើងហើយខ្ទន់ទៅ ស្រោមនៅជុំវិញបែកឃើញមានឫសចេញមក ហើយចុះត្រង់ទៅក្រោម នៅចុងឫសនេះមានរោមតូចៗ គឺរោមនេះហើយដែលជក់ស្រូបយកទឹកពីក្នុងដី ។ បន្តិចទៅឃើញដើមចេញមក ដើមនេះដុះវែងទៅលើយកខ្យល់អាកាស ហើយពកស្លឹក នៅវេលាស្លឹកដុះនោះឫសខាងក្រោមក៏បែកមានច្រើនដៃ ។ កូនឈើកាន់តែដុះធំឡើង ស្លឹកកាន់តែមានច្រើនឡើង ហើយឫសក៏កាន់តែបែកច្រើន ហើយចាក់ចុះទៅក្នុង ។ បង្រៀនមេរៀននេះ សូមគ្រូបង្គាប់សិស្សឲ្យគូរនៅក្ដារខៀនអំពីកាបានសង្កេតឃើញដូចម្ដេចៗនោះផង ទើបកាន់ចាំច្បាស់ ។

## មេទន្ទេញ

គ្រាប់រុក្ខជាតិមានពន្លកផ្សេងពីគ្នា ។ នឹងរុក្ខជាតិគេត្រាំគ្រាប់ចួនច្រាំថ្ងៃគ្រាប់ប៉ោងឡើង ហើយខ្ទន់ទៅ ឫសចាក់ចុះទៅក្រោមត្រង់ ដើមដុះវែងទៅលើ ។ ដើមមានស្លឹក ហើយឫសបែកច្រើនឡើងភ្ជាប់ដើមទៅនឹងដី ហើយរកអាហារចិញ្ចឹមដើមផង ។

## មេរៀនទី២– អង្គភាពនិងប្រយោជន៍នៃរុក្ខជាតិ

**ការពិនិត្យ**– បង្គាប់សិស្សឲ្យយកកំណាត់អំពៅឬកំណាត់ឬស្សីឬដើមស្រូវ ឬដើមដំឡូង ហើយនិងកំណាត់ដើមឈើមកពិនិត្យ ។ នាំសិស្សពិនិត្យសំបកឲ្យដឹងថារុំសាច់ ក្រាស់ឬស្តើងយ៉ាងណា ហើយពុះដើមវាមើលឃើញអ្វីខ្លះ ប្រាប់សិស្សថាដើមវានាំជ័រពីឫសទៅស្លឹកហើយទៅផ្លែ ។ ដើមនេះមានជាតិខុសគ្នា ដើមអំពៅមានជាតិផ្អែម ដើមចេកមានទឹកច្រើនណាស់ ដើមដំឡូងមានម្សៅ ។

### ដើមឈើមានសណ្ឋានខុសគ្នា

ក– ដើមឈើដែលដុះត្រង់ទៅលើអាកាសតំ

១– គ្រប់ដើមឈើដែលមានសំបកក្រាសហើយនិងសាច់រឹង ( ដើមត្នោត, ស្វា.. )
២– ដើមឈើដែលមានសំបកស្តើងហើយមានប្រហោង (ឫស្សី, ស្រូវ)
៣– ដើមរុក្ខជាតិខ្លះវារ (ស្មៅខ្លះនិងវល្លិ)
៤– ដើមខ្លះពឹងឡើងលើផ្ទង់ (ម្លូ, សណ្តែក, ម្រេច)
៥– ដើមឈើដុះនៅក្នុងដីគឺ ខ្ទឹមនិងដំឡូង ។

### មេទន្ទេញ

ដើមឈើមានសំបក សំបករុំសាច់ សាច់មានសរសៃអាចឲ្យជ័រហូរពីឫសទៅស្លឹកនិងទៅផ្លែ ចិញ្ចឹមឲ្យធំឡើង ។ ដើមឈើមានជាតិខុសគ្នា អំពៅមានជាតិផ្អែម ។ ដើមរុក្ខជាតិខ្លះដុះត្រង់ទៅលើ ខ្លះគាំងទន់ទេរ ខ្លះវារនៅដី ខ្លះឡើងលើផ្ទង់ ខ្លះនៅក្នុងដី ។ ដើមឈើមានប្រយោជន៍ទាំងអស់ ខ្លះសំរាប់ធ្វើជាអុសដុត ខ្លះធ្វើគ្រឿងផ្ទះនិងតុទូ ខ្លះទៀតមានជ័រជាប់សំខាន់គឺកៅស៊ូ ។

## មេរៀនទី ៣.– អង្គភាពនៃរុក្ខជាតិ-អំពីស្លឹក

**ការពិនិត្យ.–** បង្គាប់សិស្សឲ្យយកស្លឹករុក្ខជាតិផ្សេងៗ មកពិនិត្យ ស្លឹកមានភេទខុសគ្នាណាស់ ខ្លះធំ ខ្លះតូច ខ្លះវែង ខ្លះខ្លី ខ្លះមូល ខ្លះទ្រវែង ។ ស្លឹកស្រូវ ហើយនិងស្មៅពកវែងរុំជុំវិញដើម ។ ស្លឹកខ្លះមានបរាក់ដូចជាស្លឹកក្រាកនិងស្លឹកត្នោត ។ ស្លឹកខ្លះមានជុំវិញរលើងដូចស្លឹកម្លូ ។ ស្លឹកខ្លះទៀតមែកផែកៗជុំវិញដូចស្លឹកល្ហុង ។ ស្លឹកខ្លះមានទ្រនុងធំច្រើន ខ្លះមានទ្រនុងតិច ។ គួរតែលោកគ្រូបង្គាប់សិស្សឲ្យគូរស្លឹករុក្ខជាតិផ្សេងគ្នាខ្លះនៅក្ដារខៀន តាមដែលបានសង្កេតឃើញហើយ ។ ស្លឹកដកដង្ហើមឲ្យដើមឈើ បើគ្មានស្លឹក ដើមឈើក៏ស្លក់ហើយងាប់ទៅផង ។ ស្លឹកបញ្ចេញញើស អាចនាំចំហាយទឹកចេញពីដើមឈើ ស្លឹកចិញ្ចឹមដើមឈើស្រូបយករស់ជាតិទាំងឡាយដែលមានក្នុងអាកាស ។ ស្លឹករុក្ខជាតិខ្លះធ្វើជាចំណីអាហារមនុស្សដូចជាសាឡាត់, ម្លូ, ស្ពៃនិងបន្លែ-អន្លក់ផ្សេងៗ ស្មៅជាអាហារនៃគោ-ក្របី-សេះ ។ល។ ស្លឹកខ្លះទៀតគេប្រើជាថ្នាំដូចស្លឹកតែ, ស្លឹកគ្រសម, ស្លឹកក្រវាញ ។ល។ ស្លឹកត្នោតនិងស្លឹកស្បូវគេយកមកប្រក់ផ្ទះ ។ ស្លឹកត្រង់គេយកមកធ្វើមួកដែលក់សំពត់ ។ ស្លឹកថ្នាំគេយកមកហាន់ធ្វើជាថ្នាំមូរបារីជក់ ។

### មេរៀន

ស្លឹករុក្ខជាតិមានភេទខុសគ្នា ។ ស្លឹកដកដង្ហើមឲ្យដើមឈើ ហើយបញ្ចេញចំហាយទឹកពីដើមឈើផង ។ វាស្រូបយករស់ជាតិទាំងឡាយក្នុងអាកាស ។ ស្លឹករុក្ខជាតិមានប្រយោជន៍តាមត្រូវការ ។

# វិធីបង្ការរោគ

*អាទិត្យទី ១ .–* អំពីរបៀបលាងនិងរុំដំបៅ

<u>វត្ថុសំរាប់បង្រៀន</u> — ទឹកក្តៅ ទឹកត្រជាក់ ថ្នាំ "ប៉េរម៉ង់គាណាត ឬតាំងតួរឌីយ៉ូត" សំឡី សំពត់រុំ ។

បើយើងមិនមើលដំបៅឲ្យស្រួល នឹងក្លាយយ៉ាងឆាប់ណាស់ ព្រោះមានមេរោគនឹងធូលីមកបះពាល់ ហេតុដូច្នេះត្រូវរុំដំបៅនោះឲ្យជិត ។ មុននឹងរុំដំបៅត្រូវឲ្យសំអាតដៃនឹងសំឡីសំពត់រុំនោះទើបដំបៅនោះឆាប់ជា ។

ដើម្បីនឹងរុំដំបៅ គេដាក់ថ្នាំតាំងតួរឌីយ៉ូតបន្តិចទៅក្នុងទឹកក្តៅ គេយកសំឡីមួយដុំត្រាំក្នុងទឹកនោះ ហើយយកមកជូតដំបៅឲ្យជ្រះក្អែលកខ្វក់រួចគេគ្របមុខដំបៅនឹងកំណាត់សំពត់រុំដំបៅ ដាក់សំឡីគ្របពីលើបន្តិច ទើបគេយកសំពត់ស្អាតមករុំបង់ឲ្យជាប់មិនឲ្យរបូតបាន បើមានហើមហើយឈឺទៀតនោះ គឺមានមេរោគមានខ្ទុះនៅឡើយត្រូវលាងទៀតហើយរុំនឹងសំពត់ថ្មី ។

សេចក្ដីបង្រួម.– បើយើងមិនមើលជំងឺបៀខ្សែស្រួលនឹងភ្លាយយ៉ាងឆាប់ណាស់ ព្រោះមានមេរោគនឹងធូលីមកបះពាល់ ហេតុដូច្នេះត្រូវរុំជំងឺបៀនោះឲ្យជិត ។

## កាតិក្យទី ២.– ការពារនឹងជម្ងឺផង

ធ្វើដូចម្ដេចកុំឲ្យជម្ងឺធ្វើកាលដាលបាន

១– មុនដំបូងត្រូវយកមនុស្សឈឺដាក់ឲ្យឆ្ងាយពីគេបេញ ធ្វើកិច្ចនេះដើម្បីកុំឲ្យឆ្លងដល់អ្នកនៅជាមួយ ។ មានតែមនុស្សម្នាក់សំរាប់បំរើរក្សាអ្នកជម្ងឺ មនុស្សនោះមានសម្លៀកបំពាក់ផ្សេងពីធម្មតា ហើយកាលណាមើលជម្ងឺរួចត្រូវលាងដៃនឹងស្រា ។ សិស្សណាដែលមានជម្ងឺផងត្រូវយកបេញឲ្យឆ្ងាយពីសិស្សឯទៀត ។

២– ត្រូវសម្លាប់មេរោគ កាលដែលកំពុងមានជម្ងឺត្រូវលាងជំរះលាមកសំពត់ អាវ ខ្នើយ គ្រែ តុ កៅអី សំពត់សំរាប់រុំជំងឺបៀនោះនោងដុតចោល ។ ដល់ជម្ងឺនោះជាទៅត្រូវដុសសាប៊ូជំរះអ្នកឈឺហើយនឹងលាងជំរះរបស់ប្រើប្រាសនឹងកន្ទប ។

ដើម្បីនឹងលាងជំរះ គេប្រើថ្នាំសំរាប់សម្លាប់មេរោគដូចជាទឹកសាវ៉ែល ហ្វូម៉ុល ទឹកក្បុង ទឹកសាប៊ូ ទឹកគ្រេស៊ុល ទឹកកំបោរ ។

បើពុំនោះទេគេជំរះសម្លាប់មេរោគនឹងកំដៅក៏បាន ទឹកដោះគោ ឬទឹកផឹកនោះត្រូវដាំឲ្យពុះ ។ របស់ណាដែលអ្នកជម្ងឺប៉ះពាល់តោង បំហុយឬស្ងោរ ។ ម្យ៉ាងទៀតពន្លឺព្រះអាទិត្យសម្លាប់មេរោគឆាប់ណាស់ ហេតុដូច្នេះត្រូវបើកទ្វារបង្អួចឲ្យស្រឡះដើម្បីឲ្យពន្លឺចូល ។

## លោកនីតិ

### សម្រាប់គ្រប់ថ្នាក់

### ១ - *អំពីរបៀបតុលាការ*

គ្រប់ប្រទេសទាំងអស់មានក្រុមតុលាការ សំរាប់ជំនុំជំរះកាត់សេចក្ដី ពិន័យឬធ្វើទាសជនណាដែលប្រព្រឹត្តបទល្មើសនឹងច្បាប់ ឬកើតហេតុទាស់ទែងនឹងគ្នា ។

ប្រទេសកម្ពុជាយើងរបៀបតុលាការមានពីរបែកគឺ ក្រុមតុលាការខ្មែរនឹងក្រុមតុលាការបារាំង្ស ។ ក្រុមតុលាការខ្មែរជំនុំជំរះតែជាតិខ្មែរនឹងខ្មែរកើតវិវាទនឹងគ្នា បើខ្មែរនឹងជាតិដទៃឬជាតិដទៃដូចគ្នាកើតហេតុនឹងគ្នានោះត្រូវបែកខាងតុលាការបារាំង្សជំនុំជំរះវិញ ។

ក្រុមតុលាការខ្មែរ មានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នាយកត្រួតត្រា ហើយក្រុមទាំងនោះមានច្រើនថ្នាក់ឬបែកឯទៀតផង ដូចសាលាលហុ សាលាដំបូង - សាលាក្រុមហោទ - សាលាឧទ្ធរណ៍ - សាលាឧក្រិដ្ឋ និងសាលាសារនិប្ដ័យ ។

ស្សូរហោទ— នៅប្រទេសយើងមានក្រុមតុលាការឬទេ ។ ពីព្រោះអ្វីបានជាមានរបៀបតុលាការ ។ បើខ្មែរនឹងខ្មែរទាស់ទែងគ្នាត្រូវទៅប្ដឹងក្រសួងណាមុនដំបូង ។ បើមេឃុំផ្សះផ្សាមិនព្រមជានឹងគ្នាត្រូវទៅប្ដឹងឯណាទៀត ។ បើខ្មែរនឹងចិនឬនឹងយួនកើតវិវាទនឹងគ្នាត្រូវទៅប្ដឹងឯណា ។ រដ្ឋមន្ត្រីណាដែលនាយកលើក្រុមតុលាការទាំងអស់ ។ មានមន្ទីរនៅត្រង់ណា ។ ចូររៀបរាប់សាលាជំនុំជំរះនៅប្រទេសកម្ពុជា ។ល។

## ២- សាលាលហុ

សាលាលហុមិនមែនគេតាំងនៅគ្រប់ខេត្តទេ ខេត្តខ្លះមាន ខ្លះគ្មាន ហើយច្រើនតាំងនៅកន្លែងណា ដែលឆ្ងាយពីសាលាដំបូងផង មានចៅក្រមក្រសួងតុលាការម្នាក់ជាចាងហ្វាង ។ សាលាលហុមានអំណាចកាត់សេចក្ដីធ្វើទោសដាក់គុក កំណត់ពី១ថ្ងៃទៅដល់៥ថ្ងៃយ៉ាងច្រើន បើគូក្ដីមិនសុខចិត្តនឹងប្ដឹងសុំទៅឧទ្ធរណ៍បាន ប៉ុន្តែបើទោសល្មើសនោះត្រូវពិន័យជាប្រាក់វិញយ៉ាងតិច ៤០ សេនយ៉ាងច្រើនត្រឹម៥រៀល នោះឥតមានបើកផ្លូវឲ្យឧទ្ធរណ៍ទេ បើគូវិវាទមិនសុខចិត្តនឹងទោសដែលលក់ពិន័យនេះ នឹងមានអំណាចប្ដឹងទៅសាលាសារនិប្ដ័យបាន ។

បើរឿងណាជាបទរដ្ឋប្បវេណីគឺ ទាស់ទែងអំពីកេរ្តិ៍មរតកជាដើម ហើយថ្លៃវត្ថុនោះតិចពី ១០០រៀលចុះមក នោះសាលាលហុនឹងកាត់សេចក្ដីសម្រេចបានឥតទុកផ្លូវឧទ្ធរណ៍ បើគូក្ដីមិនសុខចិត្តនឹងសុំទៅសាលាសាវនិច្ឆ័យបាន ។ បើថ្លៃក្ដីនោះលើសពី ១០០រៀលឡើងទៅ ឬថ្លៃមិនបានច្បាស់ប្រាកដទេត្រូវកាត់សេចក្ដីទុកផ្លូវឧទ្ធរណ៍ ។ ឯរឿងឧទ្ធរណ៍ដែលគូក្ដីមិនសុខចិត្តនឹងសាលាលហុត្រូវធ្វើពាក្យឧទ្ធរណ៍យកទៅប្ដឹងសាលាដំបូងដែលសាលាលហុនោះត្រូវឡើង ។

*មេរៀនសរសេរ*.— សាលាលហុ

សាលាលហុសំរាប់ជំនុំជំរះបទលហុ គឺទោសល្មើសធ្វេសប្រហែសនឹងច្បាប់បញ្ញត្តិ មានអំណាចកាត់សេចក្ដីធ្វើទោសដាក់គុកពី ១ ថ្ងៃទៅដល់ ៥ ថ្ងៃយ៉ាងច្រើន ទុកផ្លូវឧទ្ធរណ៍ បើពិន័យជាប្រាក់វិញយ៉ាងតិចត្រឹម ៤០ សេន យ៉ាងច្រើនត្រឹម ៥ រៀលឥតទុកផ្លូវឧទ្ធរណ៍ឡើយទេ ប៉ុន្តែបើនឹងប្ដឹងទៅសាលាសាវនិច្ឆ័យបាន ។

បើរឿងក្ដីនោះចូលជាបទរដ្ឋប្បវេណីវិញ មានថ្លៃមិនលើសពី ១០០រៀលទេ សាលាលហុកាត់សេចក្ដីសម្រេចបានឥតមានទុក

ផុតឧទ្ធរណ៍ តែបើថ្លៃក្តីនោះពុំបានប្រាក់ដល់ទេ ឬលើសពី ១០០រៀលឡើងទៅ ត្រូវកាត់សេចក្តីទុកផុតឧទ្ធរណ៍ ។

សួរបោទ.— សាលាលហុច្រើនមានតាំងនៅកន្លែងណា ។ សាលាលហុសំរាប់កាត់សេចក្តីយ៉ាងណាខ្លះ ។ មានអំណាចកាត់សេចក្តីដាក់គុកបានប៉ុន្មានថ្ងៃ ។ ពិន័យប៉ុន្មានរៀល ។ បើកាត់សេចក្តីដាក់គុក ហើយអ្នកជាប់ទោសមិនសុខចិត្តត្រូវប្តឹងទៅឯណាទៀត ។ ចុះបើមិនសុខចិត្តនឹងសាលានេះពិន័យលក់វិញ ត្រូវប្តឹងទៅឯណាទៀត ។ល។

## ៣- សាលាដំបូង

សាលាដំបូងមានតាំងនៅគ្រប់ទីរួមខេត្តទាំងអស់នៃកម្ពុជរដ្ឋ សាលាដំបូងខេត្តកណ្តាល គឺសាលាលុឃុន នៅក្រុងភ្នំពេញខាងមុខព្រះបរមរាជវាំង ។

នៅសាលាដំបូងនីមួយៗ មានចៅហ្វាយសាលា មានព្រះរាជអាជ្ញា សុភាចារបុរស, ក្រឡាបញ្ជី នឹងសមុហបញ្ជី ។ សាលាដំបូងសំរាប់ជំនុំជំរះកាត់សេចក្តី រឿងអាជ្ញាគតិ បានត្រឹមតែបទមជ្ឈិមទេ គឺធ្វើទោសដាក់គុកពី ៦ ថ្ងៃទៅដល់ ៥ ឆ្នាំ នឹងពិន័យជាប្រាក់តាមកំណត់ច្បាប់សម្រេចទុកមក ។ បើនៅខេត្តណាគ្មានសាលាលហុ នោះសាលាដំបូងក៏ត្រូវជំនុំជំរះបទលហុដែរ ។

## ៤ – សាលាក្រុមហោទ

សាលាក្រុមហោទ តាំងនៅក្រុងភ្នំពេញ សំរាប់ពិនិត្យមើលពាក្យហោទផ្សេងៗ ដែលគូក្តីមិនសុខចិត្តនឹងការណ៍ជំនុំជំរះ នៅសាលាដំបូងនានា ។ លុះបានពិចារណាមើលរឿងទាំងនោះឃើញថាត្រឹមត្រូវហើយ ឬមួយនៅបន្លោះកិច្ចម្យ៉ាងៗ ពុំទាន់បានពេញសេចក្តីបរិបូណ៌ ក៏ធ្វើពណ៌ដ៏មានតាមហេតុពិនិត្យនោះ ជូនទៅសាលាឧទ្ធរណ៍ជំនុំជំរះ ។ សាលាក្រុមហោទនេះ ជាសាលាជំនួយនៃសាលាឧទ្ធរណ៍ ។

## ៥ – សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍មានតែមួយទេ តាំងនៅក្រុងភ្នំពេញ សំរាប់ពិភាក្សាកាត់សេចក្តីសាជាថ្មី ដែលគូក្តីមិនសុខចិត្តនឹងសាលាលហុ សាលាដំបូង ដែលជំនុំជំរះកាត់សេចក្តី បើកផ្លូវឧទ្ធរណ៍ អំពីបទលហុក្តី មជ្ឈិមក្តី ។

## ៦ – សាលាឧក្រិដ្ឋ

សាលាឧក្រិដ្ឋទោសសំរាប់ជំនុំជំរះទោសធ្ងន់ ដែលចូលជាបទ

ឧក្រិដ្ឋ តាំងពីទោស ៦ ឆ្នាំទៅដល់ទោសអស់ជីវិត ឬត្រូវពិឃាតជីវិតបង់ ។ បើមិនសុខចិត្តនឹងសាលក្រមសាលាឧក្រិដ្ឋទេត្រូវប្ដឹងទៅសាលាសាវិនិច្ឆ័យជាសម្រេច ។

## ៧ - សាលាសាវិនិច្ឆ័យ

សាលាសាវិនិច្ឆ័យក៏មានតែមួយ ដូចជាសាលាឧទ្ធរណ៍ និងឧក្រិដ្ឋដែរ តាំងនៅក្រុងភ្នំពេញ ជាសាលាធំបំផុត សំរាប់ពិនិត្យរឿងហេតុ នឹងជំនុំជំរះសាឡើងវិញ ក្ដីណាដែលគូវិវាទប្ដឹងសា-ទុក្ខមិនសុខចិត្តនឹងសាលក្រមសាលាលហុ, សាលាដំបូង, សាលា-ឧក្រិដ្ឋ, ឬសាលាឧទ្ធរណ៍, បើពិភាក្សាទៅឃើញថា កាត់ខុសនឹងច្បាប់ ក៏ជំនុំជំរះសាជាថ្មីឡើងវិញឲ្យបានត្រឹមត្រូវ បើឃើញថាជំនុំជំរះបានសុចរិតតាមច្បាប់ហើយ នោះត្រូវបដិសេធពាក្យបណ្ដឹងសាទុក្ខនោះចោលចេញ ។

សាលាជំនុំជំរះក្ដីក្នុងកម្ពុជរដ្ឋ ផុតអស់ត្រឹមសាលាសាវិនិច្ឆ័យនេះហើយ ។

## មេសូត្រត់មាត់

កុមារដ្ឋាន និងបរិច្ឆដ្ឋាន

## សិប្បីយការបង្កើតអំពីសិណាជាតិ

### អំបិល

ឯអំបិលនោះ គឺជាវត្ថុ ជុំរឹងពណ៌ស ឬពណ៌ប្រផេះ សណ្ឋានបែបថ្ម បើបង់សំឡរលាយទឹកបាន ។ អំបិលធ្វើសុទ្ធតែទឹកសមុទ្រមកពីបុរាណ គេបញ្ចូលទឹក ពេញស្រែស្រែបបាន បង្ខាំងប្រមាណជាច្រើនយប់ថ្ងៃ ។ គេទប់ភ្លឺស្រែ ឲ្យស្រកទឹកប្រែ ជាជុំរសប្រៃ ទឹករីងខះរឹង និងកំដៅថ្ងៃ ទើបកើបនឹងដៃ ហើយរែងឲ្យស្អាត ។ មួយទៀតគេគាស់មកហើយរំងាស់រំលាយសំអាត សំរាមដីធ្លី ពីជាតុមិនស្អាតបែបនេះមិនខាត ប្រយោជន៍ប៉ុន្មាន ។ ស្រុកលាវគេរូងដី ជ្រៅក្រហ្វង ដោយក្រហែងស្ពាន ណាដីប្រៃនោះ គេបុះយកបាន មកប្រើពុំខានខុសពីស្រុកខ្មែរ ។

---

សព្ទពន្យល់=កើបនឹងដៃ ឬ ប្រើប្រដាប់ឯណានិមួយចំនួសដៃ=ជាការប្រមូល ដាក់ក្នុងរបស់ម្យ៉ាងមានកញ្ជើនឹងល្អីជាដើម ។

— ធាតុ=ធាតុមាន ៤ គឺ ដី, ទឹក, ភ្លើង, ខ្យល់

— ក្រហែង=ប្រហោងដីប្រៃ ឬ រន្ធដី ។

# សិប្បីយការបង្កើតអំពីសិលាជាតិ (ត)

## ដីឥដ្ឋការស្មូនឆ្នាំង

ដីឥដ្ឋនេះឯង បើគិតឲ្យវែង ទៅជាតិឬដែរ កាលនៅជ្រាយទន់ បណ្តាជនខ្មែរ គេប្រើការដែរ ដូចធ្វើក្អមឆ្នាំង ។ អ្នកស្មូនប្រើពុម្ពមាន តូចមានធំ នេះពោលចាប់តាំង ពីស្រុកតុងកឹង និងយួនធ្វើឆ្នាំង ទីទៃ គ្នាខ្លាំង ពេកប្លែកពីខ្មែរ ។ នៅស្រុកព្រៃគ្រី រាស្ត្រវែងរកស៊ី លក់ក្អម ឆ្នាំងដែរ សិប្បីយការ កើតនៅស្រុកខ្មែរ ពួកស្មូននោះបែរ ជាធ្វើ និងដៃ ។ កំពង់ឆ្នាំងទៀត ក៏ប្រើបែបស្មៀត ព្រៃគ្រីរាល់ថ្ងៃ យកដីទទឹក មកទះនឹងដៃ ស្ងួនស្រែបហាលថ្ងៃ ឲ្យស្ងួតរឹងល្អ ។ ទើបគេដុតភ្លើង ឲ្យឆ្អិនសាប់ឡើង ក្រហមខ្មៅស ដើម្បីឲ្យធន់ ក្នុងការដាំស្ល ខាងក្អមវិញក៏ ដាក់ទឹកជាប់ធន់ ។

---

សព្ទពន្យល់— ស្មូន=ន. របស់ដែលកើតពីស្មូន ។

— ពុម្ពឬពិម្ព = ន. រូបប្រៀប រូបតំណាង សំណាក ។

— សិប្បីយការ = ន. មុខការដែលជាកំណើតនៃសិប្បៈ គឺៈ—ការជាងផ្សេងៗ

អាទិកដ្ឋាននឹងមធ្យមដ្ឋានទី ១

## សិប្បីយការធ្វើនឹងរុក្ខជាតិ

“ការធ្វើស្ករ”

ស្រុកខ្មែរយើងសោត គេធ្វើស្ករត្នោត មានខ្មៅមានស ដំបូងគេបង បង្អោងបន្ត ទៅទើសនឹងក ប្រគាបជាងក្រោម ។ បងជាប់ពុំលង់ គេយកបំពង់ ត្នោតមួយបង្កោម ភ្ជាប់នៅបង្កេះ ជាស្រែបពីក្រោម កាំបិតដាក់ស្រោម សៀតយ៉ាងបំណាប់ ។ បង្អោង ឬស្សីមានកាំខ្ទីៗ ដើម្បីឲ្យចាប់ជាន់ឡើងទៅលើ នោះបានយ៉ាងឆាប់ តែភ្ជាត់បំណាប់ បំណើដីបោង ។

---

សព្ទពន្យល់.— បង្អោង= ន. ឬស្សីមានកាំ សំរាប់ឡើងឈើខ្ពស់ “បង្អោងត្នោត”

— កប្រគាប= ន. ចំពាមត្រង់គល់កត្នោត ក្រោមបង្អស់ ។

— ពុំលង់= និ. ពុំយូរ

— កាំបិតដាក់ស្រោម=កាំបិតសំរាប់ចិតផ្កាត្នោតដាក់ស្រោមដូចកាំបិតស្នៀត

---

## សិប្បីយការធ្វើនឹងរុក្ខជាតិ (ត)

ការធ្វើស្ករ

លុះឡើងដល់លើ គេកាត់ផ្កាធ្វើ ជាទ្រង់ទុកត្រង ត្រង់បុងផ្កាស្រក់ តក់ៗម្តងៗ ដូច្នោះគេបង បំពង់ត្រងទឹក ។ ផ្កាត្នោតនោះស្រក់

មួយដឹងមួយតក់ មួយយប់ទាល់ព្រឹក ហាក់ដូចតិចទេ តែបានសន្លឹក មួយយប់ទាល់ព្រឹក ទុកពេញបំពង់ ។ ដាក់មករំងាស់ ខាប់ហើយ គេខ្វាស់ ស្លឹកជារង្វង់ មូលតាងពុម្ពតាក់ ជាប់តាមទម្រង់ សាប់ស្ករ ឲ្យគង់ ទ្រង់ផែនសំប៉ែត ។

សព្ទពន្យល់ — ខ្វាស់ = គឺខ្វាស់ស្លឹកត្នោតត្រាវ ឲ្យមូលធ្វើជាពុម្ព សំរាប់តាក់ស្ករ

— ផែន = គឺបន្ទះ ផ្ទាំង ដូចជា ផែនស្ករ ឬស្ករ១ផែន

## មជ្ឈិមដ្ឋានទី ២ និងឧត្តមដ្ឋាន

## ចំនក្នុងប្រទេសឥណ្ឌូចិន

បីនច្រើនជាតិណាស់ ប្រសប់គ្រប់សាស្ត្រ ធ្វើការរកស៊ី ពាណិជ្ជកម្ម ឬកាយធរណី ជាអាពជ្ជ សំភីរាល់ថ្ងៃ ។ ចិន ស្រុកខ្មែរយើង រកស៊ីដូចភ្លើង ប្រឹងជើងប្រឹងដៃ ដំដែកឈូសឈើ ធ្វើការយកថ្លៃ គ្មានមេះសំបៃ កំលាំងរាងកាយ ។ ខ្លះធ្វើជៀងស្មិត ខ្លះជាងរៀបអិដ្ឋ ផ្ទះឬទាំងឡាយ ខ្លះកាត់ស្បែកជើង ខោអាវពាក់ កាយ ផ្ទះខ្លះលក់បាយ និងស្រាគ្រប់យ៉ាង ។

សព្ទពន្យល់— ពាណិជ្ជកម្ម= របរលក់ដូរ ។

— កាយធរណី= ជីកកកាយដីដាំដំណាំ ។

— រាងកាយ= រូបកាយ ឬខ្លួនប្រាណ ។

— សំបៃកំលាំង= ថ្នមទុកកំលាំង កំ ព្រឿយហត់ ។

ចិនក្នុងប្រទេសឥណ្ឌូចិន (ត)

ចិនគ្មានទាស់ទែង ឫស្យាគ្នាឯង ដែលនៅជិតខាង សាម-
គីមិត្ត ពុំគិតក្អេងក្អាង ខ្លះមានសំណាង ឡើងជាថៅកែ ។ ស្លៀក
ខោត្រឹមភ្លៅ ដល់ចូលមកនៅ យូរទៅស្រាប់តែ មានឡានបើក
លេង បញ្ចឹះទាំងបៃ ហៅនបិតសោតប្រែ ជាគេបាៈធំ ។ ប្រាក់ប្រើ
ពុំអស់ ប្រៀបដូចរបស់ ត្រជាក់ត្រជំ ឆ្លាតខាងរកលាភ សុភាព
សមរម្យ ព្រោះការណ៍សង្គម កិច្ចគិតត្រូវគ្នា ។

---

សព្ទពន្យល់– ឫស្យា=ឈ្នានិស–ច្រណែន–បង្អាត–កាត់លាភ–កាត់ប្រយោជន៍ ។
– សាមគ្គីមិត្ត= សេចក្ដីព្រមព្រៀងស្រុះគ្នា–មិត្តមានសាមគ្គី ។
– ថៅកែ គឺ = ការៈជាអ្នកមានសម្បត្តិ ។
– បៃ= ចិនថាបង តេក្នុងសេចក្ដីនេះ សំគាល់ថាភរិយារបស់ចិន ។
– ហៅនបិត= ទីលំនៅ ។
– សង្គមកិច្ច= កិច្ចដែលរាប់រកគ្នា ។

---

## រឿងមើលកំសាន្ត

ឆ្នាំងដីការណ្ដារចាស់ (ត)

តង្កៀបអង្គប់ ដែកដាក់ពេលយប់ រុំប់ខ្ទេបក្បាលទក់ ក៏
នៅពុំដល់ នឹងដៃឆ្មាថ្ពក់ ក្របកបាប់ឈ្លក់ ឈ្លីទក់ទះខាំ ។

ឈ្លបមើលមារយាទ មុសិកជាតិ ប៉ងឃាដកម្ម ទទ្រើបតត្រុក
សំកុកប្រុងចាំ ប្រុងចាប់មិនស្កាំ ប្រុងខាំមិនស្កល់ ។ ឆ្មាបង់
កំចាយ កណ្ដុរទាំងឡាយ ដោយឧបាយកល កំចាត់ឲ្យអស់
កុំឲ្យមានសល់ ពូជក្នុងសកល នៃលោកធាតុ ។

---

សព្ទពន្យល់– មុសិកជាតិ = សត្វកណ្ដុរ ។

— ឃាតកម្ម = សម្លាប់ ។

— សកល = ផែនដីទាំងមូល ។ ឬ ពេញផែនដីទាំអស់ ។

(ប.ត.)

IMPRIMERIE
A. PORTAIL
PHNOM-PENH
TIRAGE 1.100 EX.